# ខ្លឹមសារសង្ខេបប្រតិបត្តិ
# ស្តីពី
# សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១៩

## ១- ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០១៩

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជាបន្តសម្រេចបានក្នុងអត្រា៧,១%ដែលប្រហាក់ប្រហែលនឹងកំណើនឆ្នាំ២០១៨។ នៅក្នុងឆ្នាំ២០១៩, ផសស ថ្លៃបច្ចុប្បន្នកើនឡើងដល់ **១០៩ ៨៩៤ ៩៥៩** លានរៀល សមមូលនឹងប្រមាណ **២៧ ២២២** លានដុល្លារអាមេរិក ខណៈ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ **១ ៧០៦** ដុល្លារអាមេរិក ធៀបនឹង ១ ៥៦៣ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨។ កំណើននេះត្រូវបានទ្រទ្រង់ដោយ៖ (**ទី១**)-កំណើននៃវិស័យឧស្សាហកម្មនៅបន្តរក្សាភាពរឹងមាំ ក្នុងអត្រាកំណើនប្រចាំឆ្នាំក្នុងរង្វង់១០,០%ដែលគាំទ្រដោយភាពរឹងមាំនៃវិស័យសំណង់ ការបន្តកំណើននៃវិស័យកាត់ដេរស្របគ្នានឹងសន្ទុះកំណើនខ្ពស់នៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ ទាំងសម្រាប់នាំចេញ និងបម្រើទីផ្សារក្នុងស្រុក។ អនុវិស័យសំណង់គាំទ្រដោយសន្ទុះកំណើននៃសំណង់ថ្លៃមធ្យម និងសមរម្យ តាមរយៈការអនុវត្តគម្រោងអភិវឌ្ឍន៍លំនៅដ្ឋានតម្លៃសមរម្យ និងភាពជឿជាក់ចំពោះការវិនិយោគនៅកម្ពុជា ដែលជួយប៉ះប៉ូវការធ្លាក់ចុះនៃសំណង់ថ្លៃខ្ពស់មួយផ្នែក។ វិស័យកាត់ដេរនៅបន្តកំណើនប្រហាក់ប្រហែលនឹងឆ្នាំមុន ដោយសារភាពល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក ជាពិសេសសេដ្ឋកិច្ចនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា។ ទន្ទឹមនេះ អនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ដូចជាម្ហូបអាហារនិងភេសជ្ជៈ ឧស្សាហកម្មដំឡើងយានយន្ត គ្រឿងបង្គុំអេឡិចត្រូនិក គ្រឿងបន្លាស់ គ្រឿងសង្ហារឹម កង់ និងស៊ីម៉ង់ត៍ជាដើម ទាំងសម្រាប់បម្រើឱ្យការនាំចេញ និងតម្រូវការទីផ្សារក្នុងស្រុក នឹងមានសន្ទុះកំណើនខ្ពស់ ទាំងការពង្រីកការវិនិយោគដែលមានស្រាប់ និងការវិនិយោគថ្មី។ (**ទី២**)-វិស័យសេវាកម្មនៅបន្តកំណើនប្រមាណ៧,០% ដែលគាំទ្រដោយកំណើននៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនខ្ពស់នៃចំនួនភ្ញៀវទេសចរអន្តរជាតិ ជាពិសេសមកពីតំបន់អាស៊ី ដោយសារការលើកទឹកចិត្តឱ្យមានការបើកជើងហោះហើរត្រង់កាន់តែច្រើន និងការដាក់ចេញនូវគោលនយោបាយនានាក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែម។ អនុវិស័យលក់ដុំ-រាយក៏នៅរក្សាកំណើនល្អប្រសើរ ដែលគាំទ្រដោយកំណើននៃការប្រើប្រាស់ក្នុងស្រុក ដោយសារកំណើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ អនុវិស័យអចលនទ្រព្យក៏ត្រូវបានរំពឹងថានឹងបន្តកំណើនខ្ពស់ស្របតាមនិន្នាការនៃអនុវិស័យសំណង់ផងដែរ។ ដោយឡែក អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ត្រូវបានរំពឹងថានឹងបន្តរក្សាកំណើនប្រហាក់ប្រហែលនឹងឆ្នាំ២០១៨ ដែលជំរុញដោយការអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដូចជា៖ ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ការបើកឱ្យដំណើរការឡើងវិញខ្សែផ្លូវរថភ្លើងទិសខាងជើងពីភ្នំពេញទៅប៉ោយប៉ែត ការពង្រីកព្រលានយន្តហោះ និងកំពង់ផែ

ព្រមទាំងផែនការវិនិយោគថ្មីៗលើបច្ចេកវិទ្យាជំនាន់ថ្មី (5G) លើការពង្រីកវិសាលភាពអ៊ិនធឺណិតឱ្យគ្របដណ្តប់ដល់តំបន់ដាច់ស្រយាល និង (**ទី៣**)-វិស័យកសិកម្មអាចសម្រេចបានកំណើនក្នុងរង្វង់១,៨% ដែលទ្រទ្រង់ដោយអនុវិស័យដំណាំនិងជលផល។ អនុវិស័យដំណាំត្រូវបានរំពឹងថានឹងមានកំណើនប្រហាក់ប្រហែលឆ្នាំមុនដោយសារភាពអំណោយផលនៃកត្តាអាកាសធាតុ ភាពប្រសើរឡើងនៃប្រព័ន្ធធារាសាស្ត្រ និងការកើនឡើងនៃថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិ ព្រមទាំងការកើនឡើងនៃដំណាំបម្រើឱ្យការនាំចេញផ្សេងទៀត ដូចជាកៅស៊ូ និងចេកជាដើម។ អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនល្អប្រសើរផងដែរដែលត្រូវបានជំរុញដោយការបន្តកំណើនខ្ពស់នៃអនុវិស័យវារីវប្បកម្ម ស្របតាមនិន្នាការកើនឡើងនៃការវិនិយោគពីសំណាក់វិស័យឯកជន និងការចូលរួមពីដៃគូអភិវឌ្ឍន៍។ អនុវិស័យចិញ្ចឹមសត្វក៏ត្រូវបានព្យាករថានឹងមានកំណើនល្អ ដោយសារការបន្តកំណើននៃការចិញ្ចឹមគោ និងការចិញ្ចឹមមាន់តាមបែបធម្មជាតិក្នុងគោលដៅពាណិជ្ជកម្ម ព្រមទាំងកំណើនផលិតកម្មជ្រូកដោយសារតែការងើបឡើងវិញនៃថ្លៃជ្រូករស់។

**អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ** ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ៣,១% ក្នុងឆ្នាំ២០១៩ ស្របនឹងការរំពឹងទុកនៃកំណើនយឺតនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងកំណើនយឺតជាងមុននៃថ្លៃម្ហូបអាហារ។ ចំណែកឯ**អត្រាប្តូរប្រាក់រៀល** គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៩។ **ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ)** ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៧,១% នៃ ផសស ក្នុងឆ្នាំ ២០១៩។ ភាពល្អប្រសើរឡើងនៃគណនីចរន្តនេះនឹងឆ្លុះបញ្ចាំង តាមរយៈការរំពឹងទុកនៃភាពរួមតូចនៃឱនភាពសមតុល្យពាណិជ្ជកម្ម, ការកើនឡើងខ្ពស់នៃចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងកំណើននៃប្រាក់បង្វែរឯកជនពីបរទេស (Remittances)។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ **១១ ០៥៩** លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន**៦,៥** ខែ នៅឆ្នាំ២០១៩។

ជារួម ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចដែលបានកំណត់ខាងលើ យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ។ ទោះបីយ៉ាងនេះក្តី, កម្ពុជានឹងត្រូវបន្តប្រឈមនឹងហានិភ័យដែលបណ្តាលមកពីកត្តាខាងក្រៅ និងកត្តាខាងក្នុងមួយចំនួនដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តនូវវិធានការគោលនយោបាយមុតស្រួចមួយចំនួនឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ សំដៅជម្នះ និងដោះស្រាយចំពោះរាល់បញ្ហាប្រឈម និងហានិភ័យនានា ដើម្បីធានារក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព។

## ២-ក្របខណ្ឌគោលនយោបាយថវិកាឆ្នាំ ២០១៩

ថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដូចបានគូសបញ្ជាក់ខាងលើ ព្រមជាមួយនឹងគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation) មានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពភូមិ-ឃុំ សម្រាប់ការរស់នៅដោយក្សេមក្សាន្តរបស់ប្រជាជន ព្រមទាំងការការពារឯករាជ្យ អធិបតេយ្យ និង បូរណភាពទឹកដី មិនឱ្យកម្លាំងណាមករំលោភបំពាន និងបំផ្លាញបានឡើយ ២

- ធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញ**កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** : កសាងមូលដ្ឋាន **ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០** ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង បែងចែកផ្លែផ្កាកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានាសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន ចីរភាព និងធន់នឹងវិបត្តិ ព្រមទាំងធានាបានស្ថិរភាពហិរញ្ញវត្ថុជាទូទៅ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបអាចគ្រប់គ្រង បាន និងអត្រាប្តូរប្រាក់មានស្ថិរភាព
- បន្តគាំទ្រដល់ការអនុវត្តការកែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ដើម្បីអភិបាលកិច្ចល្អ ជាពិសេសការ-កែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់វិស័យកងកម្លាំងប្រដាប់-អាវុធ ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥
- បន្តគិតគូរ និងដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកម្រិតសមស្របជូនដល់មន្ត្រីរាជការទូទៅព្រមទាំងបង្កើនប្រាក់សោធនជូននិវត្តជន និងអតីតយុទ្ធជន និងផ្តល់អាទិភាពលើការដំឡើងប្រាក់បំណាច់មុខងារជូនដល់មន្ត្រីក្នុងកម្រិតគ្រប់គ្រង និងមន្ត្រីដែលមានជំនាញខ្ពស់ ក្នុងក្របខណ្ឌនៃការផ្សារភ្ជាប់ការកែទម្រង់រដ្ឋបាលសាធារណៈទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បន្តអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ជាពិសេសការដាក់ឱ្យអនុវត្តនូវកម្មវិធីគាំពារសង្គមជាអាទិភាពមួយចំនួន រួមមាន៖ (១)-កម្មវិធីសង្គហទានសង្គមសម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច, (២)-របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និង (៣)-របបសោធនសម្រាប់កម្មករនិយោជិត
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី តាមរយៈការជំរុញវិនិយោគសាធារណៈ ឱ្យគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសាធារណៈចាំបាច់ សម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលកម្មជំនាញប្រកបដោយផលិតភាពឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរកិច្ច
- បន្តលើកកម្ពស់សេវាសុខាភិបាល តាមរយៈការបង្កើនការវិនិយោគបន្ថែម ទាំងលើអគារមន្ទីរពេទ្យ សម្ភារបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល
- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្តោតសំខាន់លើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន វិស័យថាមពល និងវិស័យឌីជីថល ដោយក្នុងនោះ ថ្លៃអគ្គិសនី នឹងត្រូវបានបញ្ចុះ ទៅតាមកម្មវិធី និងតារាងថ្លៃជាក់លាក់សម្រាប់ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ដើម្បីជំរុញការលូតលាស់ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យសេវាកម្ម
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព ពិពិធកម្ម ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម
- ពង្រឹងលំហថវិកា និងយន្តការគ្រប់គ្រងហានិភ័យ ដែលអាចកើតមានឡើងជាយថាហេតុ

- បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥
- បន្តគ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព សំដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប
- គាំទ្រដល់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ
- បន្តពង្រឹងស្ថាប័នជាតិ និងអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព និងតម្លាភាពនៃសេវាសាធារណៈ ដើម្បីទទួលបាននូវការជឿទុកចិត្តកាន់តែខ្លាំងឡើងថែមទៀតពីសំណាក់ប្រជាជន។

ដើម្បីសម្រេចបាននូវគោលបំណងសំខាន់ៗខាងលើ ថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយប្រកាន់យកគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ៗ ចំនួន ៤ និងគោលការណ៍បច្ចេកទេសសំខាន់ៗ ចំនួន ៧ ដូចខាងក្រោម៖

**ក. គោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ៗ ៖**

- ធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន, ផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកើនឡើងកាន់តែខ្ពស់ និងបង្កើនចំណូលថវិកាជាតិ
- ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ
- បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជនតាមការសន្យា ក៏ដូចជា ការពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និង សមត្ថភាពនៃវិស័យសាធារណៈ ដើម្បីពង្រីកវិសាលភាព និងពង្រឹងគុណភាពនៃសេវាសាធារណៈ និង សេវាយុត្តិធម៌
- ផ្តល់ការលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នណា ដែលអនុវត្តសកម្មភាពការងាររបស់ខ្លួនប្រកបដោយបុរេសកម្ម និង មានសមិទ្ធកម្ម ឬ លទ្ធផលការងារល្អ។

**ខ. គោលការណ៍បច្ចេកទេសសំខាន់ៗ ៖**

- ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល
- ការកំណត់លំដាប់អាទិភាព
- ការយកចិត្តទុកដាក់លើមនុស្ស
- ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព
- ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត
- ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា
- ការរក្សាតុល្យភាព និងចីរភាពថវិកា។

## ៣-ក្របខណ្ឌថវិកាឆ្នាំ ២០១៩

ឈរលើគោលការណ៍ខាងលើ ក៏ដូចជាក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៧,០% ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដោយឈរលើមូលដ្ឋាននៃលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូល ជាពិសេស ចំណូលគយ និងចំណូលពន្ធដារឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ នេះ, ក្របខណ្ឌថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើង ក្រោមការកំណត់ដូចតទៅ៖

| សូចនាករថវិកា | ២០១៧ | | ២០១៨ | ២០១៩ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| **ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **18.51** | **20.24** | **18.71** | **19.28** |
| - ចំណូលចរន្ត (% ផសស) | 18.35 | 20.08 | 18.53 | 19.10 |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **23.57** | **23.45** | **24.54** | **24.72** |
| - ចំណាយចរន្ត (% ផសស) | 15.37 | 15.66 | 16.05 | 16.30 |
| **អតិរេកចរន្ត (% ផសស)** | **2.97** | **4.43** | **2.48** | **2.81** |
| **ឱនភាពសរុប (% ផសស)** | **-5.05** | **-3.21** | **-5.83** | **-5.44** |

**ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ** ត្រូវបានគ្រោងចំនួន ២១ ១៨៦ ២២៨ លានរៀល ស្មើនឹង ១៩,២៨% នៃ ផសស និងមានកំណើន ១៤,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ចំណែកឯ **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ** ត្រូវបានគ្រោងចំនួន ២៧ ១៦៤ ៩៩៦ លានរៀល ស្មើនឹង ២៤,៧២% នៃ ផសស និងមានកំណើន ១១,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។ ជាលទ្ធផល **អតិរេកថវិកាចរន្ត** អាចរក្សាបានក្នុងកម្រិតប្រមាណ **២,៨១%** នៃ ផសស នៅឆ្នាំ ២០១៩ និងមាន **ឱនភាពថវិកាសរុប** ស្មើនឹង **-៥,៤៤%** នៃ ផសស ស្របតាមគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation)។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៤,៨៤% នៃ ផសស, មូលនិធិទ្រទ្រង់ថវិកាប្រមាណ ០,២៣% នៃ ផសស និងប្រាក់បញ្ញើរាជរដ្ឋាភិបាលក្នុងទំហំ ០,៣៧% នៃ ផសស ស្មើនឹង **៤០៥ ០០០ លានរៀល ឬ សមមូលនឹង ១០០ លានដុល្លារអាមេរិក** ដែលត្រូវបានគ្រោងយកមកប្រើប្រាស់សម្រាប់ផ្តល់ទុនដល់ការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម (SMEs Bank) របស់រដ្ឋ។ ដូច្នេះ បើមិនគិតអំពីតម្រូវការទុនសម្រាប់បង្កើតធនាគារធុនតូច និងមធ្យមនេះទេ គឺ**ថវិកាឆ្នាំ ២០១៩ មានតុល្យភាព ដោយមិនចាំបាច់ប្រើប្រាក់បញ្ញើ ឬ ហៅថា "ប្រាក់សន្សំ" របស់រាជរដ្ឋាភិបាលនោះទេ**។

## ៤.-គម្រោងចំណូល-ចំណាយថវិការដ្ឋ

### ៤.១-គម្រោងចំណូលថវិការដ្ឋ

| ចំណូលថវិកា (ឯកតាលានរៀល) | ២០១៨ | | ២០១៩ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណូលថវិការដ្ឋ ឬ ថវិកាជាតិ** | **23,383,942** | **23.54%** | **26,759,996** | **24.35%** | **14.4%** |
| • *ថ្នាក់ជាតិ* | 22,437,138 | 22.59% | 25,360,028 | 23.08% | 13.0% |
| • *ថ្នាក់ក្រោមជាតិ* | 946,804 | 0.95% | 1,399,968 | 1.27% | 47.9% |
| **១. ចំណូលចរន្តថវិការដ្ឋ** | **18,406,810** | **18.53%** | **20,993,079** | **19.10%** | **14.1%** |
| ***ក. ចំណូលសារពើពន្ធថវិការដ្ឋ*** | **15,986,005** | **16.09%** | **18,230,617** | **16.59%** | **14.0%** |
| - *ថ្នាក់ជាតិ* | 15,075,562 | 15.18% | 16,879,000 | 15.36% | 12.0% |
| - *ថ្នាក់ក្រោមជាតិ* | 910,443 | 0.92% | 1,351,617 | 1.23% | 48.5% |
| ***ខ. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ*** | **2,420,805** | **2.44%** | **2,762,462** | **2.51%** | **14.1%** |
| - *ថ្នាក់ជាតិ* | 2,384,444 | 2.40% | 2,714,111 | 2.47% | 13.8% |
| - *ថ្នាក់ក្រោមជាតិ* | 36,361 | 0.04% | 48,351 | 0.04% | 33.0% |
| **២. ចំណូលមូលធនថវិការដ្ឋ** | **4,977,132** | **5.01%** | **5,766,917** | **5.25%** | **15.9%** |
| • *ក្នុងប្រទេស* | 180,193 | 0.18% | 193,149 | 0.18% | 7.2% |
| • *ក្រៅប្រទេស* | 4,796,939 | 4.83% | 5,573,768 | 5.07% | 16.2% |

ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវ**បង្កើនចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ** ឱ្យស្មើនឹង ២៦ ៧៥៩ ៩៩៦ លានរៀល ក្នុងនោះ ចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង ១៩ ៥៩៣ ១១១ លានរៀល (ដែលរួមមាន ចំណូលសារពើពន្ធ ១៦ ៨៧៩ ០០០ លានរៀល និង ចំណូលមិនមែនសារពើពន្ធ ២ ៧១៤ ១១១ លានរៀល)។ ដោយឡែក សម្រាប់ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៥ ៧៦៦ ៩១៧ លានរៀល, ត្រូវជា ៥,២៥% នៃ ផសស គឺមានកំណើន ១៥,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ក្នុងនោះចំណូលមូលធនដោយហិរញ្ញប្បទានពីក្រៅប្រទេស ស្មើនឹងប្រមាណ ២០% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០១៩ ប៉ុណ្ណោះ។

### ៤.២-គម្រោងចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០១៩ **ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន **២៧ ១៦៤ ៩៩៦ លានរៀល** ត្រូវជា ២៤,៧២% នៃ ផសស គឺមានកំណើន ១១,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ដែលក្នុងនោះ: **(១)-ចំណាយចរន្តថវិការដ្ឋមានចំនួន ១៧ ៩០៧ ៥៤៩ លានរៀល** ត្រូវជា ១៦,៣០% នៃ ផសស គឺមានកំណើន ១២,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ និង **(២)-ចំណាយមូលធនថវិការដ្ឋមានចំនួន ៩ ២៥៧ ៤៤៧ លានរៀល** ត្រូវជា ៨,៤២% នៃ ផសស គឺមានកំណើន ៩,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។

| ចំណាយថវិកា (ឯកតាលានរៀល) | ២០១៨ | | ២០១៩ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណាយថវិការដ្ឋ ឬ ថវិកាជាតិ** | **24,375,102** | **24.54%** | **27,164,996** | **24.72%** | **11.4%** |
| *• ថ្នាក់ជាតិ* | 23,428,298 | 23.59% | 25,765,028 | 23.45% | 10.0% |
| *• ថ្នាក់ក្រោមជាតិ* | 1,684,674 | 1.70% | 2,199,636 | 2.00% | 30.6% |
| **១. ចំណាយចរន្តថវិការដ្ឋ** | **15,945,418** | **16.05%** | **17,907,549** | **16.30%** | **12.3%** |
| ***១.១. ថ្នាក់ជាតិ*** | **15,218,166** | **15.32%** | **16,827,280** | **15.31%** | **10.6%** |
| *•បន្ទុកបុគ្គលិក* | 7,914,924 | 7.97% | 7,862,537 | 7.15% | -0.7% |
| *•ក្រៅបន្ទុកបុគ្គលិក* | 7,303,243 | 7.35% | 8,964,743 | 8.16% | 22.8% |
| ***១.២. ថ្នាក់ក្រោមជាតិ*** | **1,465,122** | **1.47%** | **1,879,937** | **1.71%** | **28.3%** |
| *•បន្ទុកបុគ្គលិក* | 388,044 | 0.39% | 472,565 | 0.43% | 21.8% |
| *•ក្រៅបន្ទុកបុគ្គលិក* | 1,077,078 | 1.08% | 1,407,372 | 1.28% | 30.7% |
| **២. ចំណាយមូលធនថវិការដ្ឋ** | **8,429,684** | **8.49%** | **9,257,447** | **8.42%** | **9.8%** |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 3,145,352 | 3.17% | 3,027,731 | 2.76% | -3.7% |
| *+ ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ* | *219,552* | *0.22%* | *319,699* | *0.29%* | *45.6%* |
| *- ការទូទាត់ប្រាក់ខ្ចី* | 737,393 | 0.74% | 905,948 | 0.82% | 22.9% |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 4,546,939 | 4.58% | 5,323,768 | 4.84% | 17.1% |

## ៤.២.១-ថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០១៩ មានទិសដៅជាយុទ្ធសាស្ត្រកំណត់**ចំណាយថវិកាថ្នាក់ជាតិ**ឱ្យស្ថិតក្នុងកម្រិតចំនួន ២៥ ៧៦៥ ០២៨ លានរៀល ត្រូវជា ២៣,៤៥% នៃ ផសស គឺមានកំណើន ១០,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ដែលក្នុងនោះ **ចំណាយចរន្តថ្នាក់ជាតិ** មានចំនួន ១៦ ៨២៧ ២៨០ លានរៀល និង **ចំណាយមូលធនថ្នាក់ជាតិ**មានចំនួន ៨ ៩៣៧ ៧៤៨ លានរៀល។

**ក. ចំណាយលើបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ៧ ៨៦២ ៥៣៧ លានរៀល សម្រាប់(១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១០,០% តាមតម្លៃឯកតាសន្ទស្សន៍ ២ ៣៤០ រៀល ដោយអនុវត្ត ចាប់ពីខែមករា ឆ្នាំ ២០១៩, (២)-ការដំឡើងប្រាក់បំណាច់មុខងារនឹងត្រូវអនុវត្តចាប់ពីខែមេសា ឆ្នាំ ២០១៩ ដោយផ្តល់បន្ថែម ៣០ ០០០ រៀល ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ៧៥០ ០០០ រៀល ចុះក្រោម, (៣)-ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាពី ៦០០ ០០០ រៀល ទៅដល់ ៦៥០ ០០០ រៀល ដោយអនុវត្តចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០១៩។

ជារួម នៅឆ្នាំ ២០១៩ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ នឹងមានស្ថានភាពផ្លាស់ប្តូរដូចខាងក្រោម៖

- **បៀវត្សមន្ត្រីរាជការស៊ីវិល** នឹងត្រូវបានដំឡើងពីចំនួន ១ ០១៤ ៤៥០ រៀល នៅឆ្នាំ ២០១៨ ដល់ប្រមាណ ១ ០៧០ ១០០ រៀល នៅខែមករា ឆ្នាំ ២០១៩, ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ១០០ ១០០** រៀល ចាប់ពីខែមេសា ឆ្នាំ ២០១៩;

- **បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ** នឹងត្រូវបានដំឡើងពីចំនួន ១ ១១៤ ៤៥០ រៀល នៅឆ្នាំ ២០១៨ ដល់ប្រមាណ ១ ១៧០ ១០០ រៀល នៅខែមករា ឆ្នាំ ២០១៩ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ២០០ ១០០** រៀល ចាប់ពីខែមេសា ឆ្នាំ ២០១៩;
- **បៀវត្សនគរបាល (ពលបាលត្រី)** នឹងត្រូវបានដំឡើងពីចំនួន ១ ០៩៨ ៩២៧ រៀល (គិតបញ្ចូលទាំងរបបអង្គរ) នៅឆ្នាំ ២០១៨ ដល់ប្រមាណ ១ ១៥៤ ៥៧៧ រៀល (គិតបញ្ចូលទាំងរបបអង្គរ) នៅខែមករា ឆ្នាំ ២០១៩ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ១៨៤ ៥៧៧** រៀល (គិតបញ្ចូលទាំងរបបអង្គរ) ចាប់ពីខែមេសា ឆ្នាំ ២០១៩;
- **បៀវត្សយោធិន (ពលទោ)** នឹងត្រូវបានដំឡើងពីចំនួន ៩៧៦ ៥៥០ រៀល (មិនគិតបញ្ចូលរបបអង្គរ) នៅឆ្នាំ ២០១៨ ដល់ប្រមាណ ១ ០២៥ ៩០០ រៀល (មិនគិតបញ្ចូលរបបអង្គរ) នៅខែមករា ឆ្នាំ ២០១៩ ហើយនឹងត្រូវបានដំឡើងដល់ ១ ០៥៥ ៩០០ រៀល ចាប់ពីខែមេសា ឆ្នាំ ២០១៩ បើគិតបញ្ចូលរបបអង្គរ ត្រូវជាប្រមាណ **១ ១១៤ ៣៧៧** រៀល។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន**៥០ប៊ីលានរៀល** ជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជននៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។ ទន្ទឹមគ្នានេះ បន្ថែមពីលើប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួនពីរ គឺប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី និងប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការដែលទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ ដើម្បីរៀបចំពិធីបុណ្យសពតាមប្រពៃណី ដែលត្រូវបានដាក់ឱ្យអនុវត្តនៅដើមឆ្នាំ២០១៨, រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន**៦ ប៊ីលានរៀល**ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។ ចំពោះប្រាក់សោធននិវត្ត ក៏ត្រូវបានគ្រោងថវិកា**ចំនួន៦០ប៊ីលានរៀល** សម្រាប់ការដំឡើងរបបសោធនប្រចាំខែទាបបំផុត និងការកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកទទួលបានសោធនទាប និងអ្នកទទួលបានសោធនខ្ពស់ និងរវាងនិវត្តជនថ្មី និងនិវត្តជនចាស់ ជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធផងដែរ។

**ខ. <u>ចំណាយមិនមែនបន្ទុកបុគ្គលិក</u>** ត្រូវបានគ្រោងចំនួន ៨ ៩៦៤ ៧៤៣ លានរៀល, មានសមាមាត្រស្មើនឹង ៥៣,២៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៨,១៦% នៃ ផសស គឺមានកំណើន ២២,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ហើយត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម៖

**<u>វិស័យរដ្ឋបាលទូទៅ</u>**

- លើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- គាំទ្រកំណែទម្រង់វិស័យដីធ្លី

- គាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
- គាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- បង្កើនប្រសិទ្ធភាពនៃកិច្ចការទូត តាមរយៈបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ត្រីការទូត។

## វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ
- បង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ
- គាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ
- គាំទ្រការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព
- គាំទ្រដល់ប្រតិបត្តិការផលិតអត្តសញ្ញាណប័ណ្ណ
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

## វិស័យសង្គមកិច្ច

- ពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ
- អភិវឌ្ឍជំនាញ និងវិស័យការងារ
- លើកកម្ពស់គុណភាពសេវាសុខាភិបាល
- ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ
- ឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន
- បង្កើនការឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី ខេត្ត និងការឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា ដើម្បីផ្តល់សេវាជូនជនពិការ
- ផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រនៅតាមសហគមន៍ក្នុងដំហានសាកល្បង
- ការពារ និងអភិរក្សធនធានធម្មជាតិ
- អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ
- សុខដុមនីយកម្មសាសនា។

## វិស័យសេដ្ឋកិច្ច

- បន្តការលើកកម្ពស់បច្ចេកទេសកសិកម្ម
- ជំរុញផលិតកម្មស្បៀង ពិសេសការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម

- ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល
- បង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ
- ជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ
- ជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា
- បណ្តុះបណ្តាលធនធានមនុស្ស
- បន្តជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត
- ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- អភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិក
- ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- អភិវឌ្ឍប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

លើសពីនេះ សម្រាប់ឆ្នាំ ២០១៩ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកា ឆ្លើយតបនឹងសកម្មភាពគាំពារសង្គម ដែលរួមមានជាអាទិ៍ ដូចជា៖

- **បន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ៖** បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ។
- **បន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត៖** បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព។
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា៖** បានគ្រោងថវិកានៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់បង្កើន "**មូលនិធិគន្ធបុប្ផាកម្ពុជា**", បន្ថែមលើថវិកាដែលត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០១៩, ដើម្បីធានានិរន្តភាព គុណភាព និងប្រសិទ្ធភាពរបស់មន្ទីរពេទ្យផង និងធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រផង។
- **ការបន្តសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការចុះសួរសុខទុក្ខកម្មករ-កម្មការិនី** តាមបណ្តារោងចក្រ សហគ្រាស ដើម្បីស្វែងយល់និងរកដំណោះស្រាយសមស្របជូនកម្មករ-កម្មការិនី ក៏ដូចជាជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

- **កម្មវិធីសង្គហទានសង្គមសម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច៖** បានគ្រោងថវិកាសម្រាប់ឧបត្ថម្ភពេលពិនិត្យផ្ទៃពោះ ចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល, ពេលសម្រាលកូននៅមណ្ឌលសុខភាព ឬ ពេទ្យរដ្ឋ ជូន ២០ម៉ឺនរៀល, ឧបត្ថម្ភ ១០ លើកទៀត ១លើក ៤ ម៉ឺនរៀល ពេលទៅទទួលថ្នាំបង្ការ រហូតដល់កុមារអាយុ ២ ឆ្នាំ។

**គ. ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន ៨ ៩៣៧ ៧៤៨ លានរៀល មានសមាមាត្រស្មើនឹង ៣៤,៧% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា ៨,១៣% នៃ ផសស គឺមានកំណើន ៨,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។ គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិថយចុះ -៧,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ហើយត្រូវជា ២,៤៦% នៃ ផសស, ដែលការធ្លាក់ចុះនេះ គឺដោយសារការអនុវត្តគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា។ ប៉ុន្តែគួរកត់សំគាល់ថា ការថយចុះនេះតែលើចំណាយវិនិយោគដែលមិនគាំទ្រផ្ទាល់ដល់កំណើននិងភាពប្រកួតប្រជែងកម្ពុជា ដូចជាការសាងសង់អគាររដ្ឋបាលជាដើម, ដោយឡែក ចំណាយលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងកម្ពុជាមិនថយចុះទេ ហើយចំណាយនេះមានគោលដៅផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធីក្នុងវិស័យអាទិភាពដោយផ្តោតទៅលើការទ្រទ្រង់កំណើនសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ដូចជា៖

- ការកសាង និងជួសជុលផ្លូវថ្នល់ ជាពិសេសការស្តារនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់, និងកសាងកំពង់ផែទន្លេ
- ការបន្តស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ពិសេសលើកកម្ពស់ការគ្រប់គ្រង និងទប់ទល់នឹងទឹកជំនន់
- ការបន្តសាងសង់ និង ជួសជុលសាលារៀននៅតាមបណ្តាខេត្ត
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, វិស័យគមនាគមន៍ និងដឹកជញ្ជូន និងវិស័យអាទិភាពផ្សេងៗទៀត ដូចជា សុខាភិបាល និងការផ្គត់ផ្គង់ទឹកស្អាត ជាដើម
- ការបន្តអនុវត្តសាកល្បងនូវកម្មវិធីសាច់ប្រាក់ពលកម្ម ( Cash For Work ) ដែលជាអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើតការងារនៅទីជនបទ
- ការបន្តវិនិយោគលើវិស័យអគ្គិសនី ដើម្បីបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ
- ការផ្តល់ថវិកាគម្រោងវិនិយោគផ្ទាល់ក្នុងខេត្តត្បូងឃ្មុំ
- ការបន្តវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្ម និងការវិនិយោគលើការជំរុញផលិតកម្មស្បៀង ជាពិសេសការផលិតស្រូវ និងបន្លែ

ជាលទ្ធផលរួម ថវិកាថ្នាក់ជាតិត្រូវបានបែងចែកទៅតាមវិស័យទាំង ៤ ដូចខាងក្រោម៖

| ចំណាយថវិកាតាមវិស័យ (ឯកតាលានរៀល) | ២០១៨ | | ២០១៩ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **១. វិស័យរដ្ឋបាលទូទៅ** | **2,453,008** | **2.47%** | **2,463,542** | **2.24%** | **0.4%** |
| **ក. ចំណាយចរន្ត** | **2,263,304** | **2.28%** | **2,245,785** | **2.04%** | **-0.8%** |
| -បន្ទុកបុគ្គលិក | 626,302 | 0.63% | 692,538 | 0.63% | 10.6% |
| -ក្រៅបន្ទុកបុគ្គលិក | 1,637,002 | 1.65% | 1,553,247 | 1.41% | -5.1% |
| **ខ. ចំណាយមូលធន** | **189,704** | **0.19%** | **217,757** | **0.20%** | **14.8%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 16,500 | 0.02% | 16,500 | 0.02% | 0.0% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 173,204 | 0.17% | 201,257 | 0.18% | 16.2% |
| **២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | **4,005,665** | **4.03%** | **4,425,150** | **4.03%** | **10.5%** |
| **ក. ចំណាយចរន្ត** | **3,894,376** | **3.92%** | **4,263,557** | **3.88%** | **9.5%** |
| -បន្ទុកបុគ្គលិក | 3,063,664 | 3.08% | 3,387,865 | 3.08% | 10.6% |
| -ក្រៅបន្ទុកបុគ្គលិក | 830,712 | 0.84% | 875,692 | 0.80% | 5.4% |
| **ខ. ចំណាយមូលធន** | **111,289** | **0.11%** | **161,593** | **0.15%** | **45.2%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 54,600 | 0.05% | 79,417 | 0.07% | 45.5% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 56,689 | 0.06% | 82,176 | 0.07% | 45.0% |
| **៣. វិស័យសង្គមកិច្ច** | **7,014,100** | **7.06%** | **7,249,418** | **6.60%** | **3.4%** |
| **ក. ចំណាយចរន្ត** | **5,658,959** | **5.70%** | **6,196,796** | **5.64%** | **9.5%** |
| -បន្ទុកបុគ្គលិក | 3,765,808 | 3.79% | 3,263,876 | 2.97% | -13.3% |
| -ក្រៅបន្ទុកបុគ្គលិក | 1,893,151 | 1.91% | 2,932,920 | 2.67% | 54.9% |
| **ខ. ចំណាយមូលធន** | **1,355,140** | **1.36%** | **1,052,622** | **0.96%** | **-22.3%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 420,000 | 0.42% | 280,000 | 0.25% | -33.3% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 935,140 | 0.94% | 772,622 | 0.70% | -17.4% |
| **៤. វិស័យសេដ្ឋកិច្ច** | **5,666,091** | **5.70%** | **6,620,459** | **6.02%** | **16.8%** |
| **ក. ចំណាយចរន្ត** | **1,379,185** | **1.39%** | **1,506,888** | **1.37%** | **9.3%** |
| -បន្ទុកបុគ្គលិក | 459,150 | 0.46% | 518,258 | 0.47% | 12.9% |
| -ក្រៅបន្ទុកបុគ្គលិក | 920,035 | 0.93% | 988,630 | 0.90% | 7.5% |
| **ខ. ចំណាយមូលធន** | **4,286,907** | **4.32%** | **5,113,572** | **4.65%** | **19.3%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 905,000 | 0.91% | 845,858 | 0.77% | -6.5% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 3,381,907 | 3.40% | 4,267,714 | 3.88% | 26.2% |


ទំហំកំណើនចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន
សម្រាប់ឆ្នាំ ២០១៩ ធៀបនឹងឆ្នាំ ២០១៣
2,580,008
1,400,969
1,067,719
963,243
585,187
511,322
486,322
322,779
205,396
202,775
151,775
144,710
134,220
ក្រសួងអប់រំ យុវជន និងកីឡា
ក្រសួងការពារជាតិ
ក្រសួងមហាផ្ទៃ
ក្រសួងសុខាភិបាល
ក្រសួងសាធារណការនិងដឹកជញ្ជូន
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្រសួងរ៉ែនិងថាមពល
ក្រសួងអភិវឌ្ឍន៍ជនបទ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ


ចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន
សម្រាប់ឆ្នាំ ២០១៣-២០១៩
(ចំណាយចរន្ត និង ចំណាយមូលធន)
ឯកតាលានរៀល
ចំណាយចរន្ត
ចំណាយមូលធន
1,081,662
3,661,670
1,015,469
2,416,438
783,667
1,851,386
857,682
1,820,925
2,409,136
2,994,323
496,069
1,007,391
342,193
828,515
143,349
466,128
311,799
517,195
546,320
749,096
56,071
207,846
45,881
190,592
124,640
258,860
២០១៣
២០១៩
ក្រសួងអប់រំ យុវជន និងកីឡា
ក្រសួងការពារជាតិ
ក្រសួងមហាផ្ទៃ
ក្រសួងសុខាភិបាល
ក្រសួងសាធារណការនិងដឹកជញ្ជូន
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្រសួងរ៉ែនិងថាមពល
ក្រសួងអភិវឌ្ឍន៍ជនបទ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ៤.២.២-ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ឯកតាលានរៀល) | ២០១៨ | | ២០១៩ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ** | **946,804** | **0.95%** | **1,399,968** | **1.27%** | **47.9%** |
| • *ចំណូលសារពើពន្ធ* | 910,443 | 0.92% | 1,351,617 | 1.23% | 48.5% |
| • *ចំណូលមិនមែនសារពើពន្ធ* | 36,361 | 0.04% | 48,351 | 0.04% | 33.0% |
| **សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ** | **1,684,674** | **1.70%** | **2,199,636** | **2.00%** | **30.6%** |
| • *ចំណាយចរន្ត* | 1,465,122 | 1.47% | 1,879,937 | 1.71% | 28.3% |
| • *ចំណាយមូលធន* | 219,552 | 0.22% | 319,699 | 0.29% | 45.6% |
| ឱនភាពថវិកា | -737,870 | -0.74% | -799,668 | -0.73% | 8.4% |
| **ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ** | **737,870** | **0.74%** | **799,668** | **0.73%** | **8.4%** |
| • *រាជធានី-ខេត្ត* | 148,814 | 0.15% | 83,808 | 0.08% | -43.7% |
| • *មូលនិធិក្រុង-ស្រុក* | 155,015 | 0.16% | 192,060 | 0.17% | 23.9% |
| • *មូលនិធិឃុំ-សង្កាត់* | 434,041 | 0.44% | 523,800 | 0.48% | 20.7% |

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត មូលនិធិក្រុង-ស្រុក និង មូលនិធិឃុំ-សង្កាត់ មានឱនភាពថវិកាចំនួន ៧៩៩ ៦៦៨ លានរៀល ដែលត្រូវបានឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ហើយការឧបត្ថម្ភនេះមានកំណើន ៨,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ត្រូវជា ០,៧៣%នៃ ផសស ក្នុងនោះ ឧបត្ថម្ភធនមូលនិធិក្រុង-ស្រុក កើនចំនួន ២៣,៩% និង ឧបត្ថម្ភធនមូលនិធិឃុំ-សង្កាត់កើនចំនួន ២០,៧%។

ជាមួយនឹងការបង្កើនចំណាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ, អាទិភាពចំណាយត្រូវបានផ្តល់ដល់ការដំឡើងប្រាក់បំណាច់ជូនដល់ក្រុមប្រឹក្សារាជធានី ខេត្ត, ក្រុង ស្រុក ខណ្ឌ, ឃុំ សង្កាត់ និង មន្ត្រីភូមិ ផងដែរ។

## ៤.២.៣-ស្ថានភាពបំណុល

ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលតែងតែប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ០៤ ដូចខាងក្រោម៖

(១). ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

(២). ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

(៣). ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬ ផលិតភាពផលិតកម្ម

(៤). ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និង ស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០១៩ ក្នុងកម្រិត ១ ៤០០លាន អេសដេអ៊ែរ ដោយសំអាងទៅលើទិដ្ឋភាពសំខាន់ៗគឺ៖ (១)-ទំហំនៃតម្រូវការអភិវឌ្ឍន៍មានការកើនឡើង, (២)-គម្រោងអភិវឌ្ឍន៍ដែលនឹងចុះកិច្ចព្រមព្រៀងឥណទានសម្បទានក្នុងឆ្នាំ ២០១៩ ជាគម្រោងវិនិយោគ

សាធារណៈក្នុងវិស័យអាទិភាព (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបង្កើនផលិតភាពសេដ្ឋកិច្ច ព្រមទាំងផលិតភាពផលិតកម្ម)ហើយដែលចេះតែរំកិលពីឆ្នាំមុនៗមក តែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង, (៣)-ឥណទានមានកម្រិតសម្បទានខ្ពស់, (៤)-ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមនៅតែមាន "ចីរភាព" និង "ហានិភ័យកម្រិតទាប" និង (៥)-បន្តផ្តល់ប្រសិទ្ធភាពខ្ពស់លើការគ្រប់គ្រង និងអនុវត្តគម្រោង ។ ជារួម ការបង្កើនទំហំនៃការខ្ចីនេះ នឹងមិនបង្កើតជាបន្ទុកបំណុលណ្ណែកដល់កម្ពុជាទេ ព្រោះថានៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើននោះសមត្ថភាពសងរបស់កម្ពុជាក៏ខ្ពស់ជាងមុនដែរ។ ជាក់ស្តែង លទ្ធផលនៃការវិភាគចីរភាពបំណុល ដោយឈរលើមូលដ្ឋានសន្មតនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ ២០១៩ ក្នុងកម្រិត១ ៤០០លានអេសដេអ៊ែរ គឺបានបង្ហាញថាអនុបាតបំណុល គន្លឹះទាំង៤របស់កម្ពុជាសុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

ក្នុងន័យនេះ ការកំណត់ពិដានក្នុងការខ្ចីថ្មីសម្រាប់ឆ្នាំ ២០១៩ ក្នុងកម្រិត១ ៤០០លានអេសដេអ៊ែរ គឺដើម្បីឱ្យរាជរដ្ឋាភិបាលអាចចុះហត្ថលេខាខ្ចីប្រាក់ពីគេបានចំនួន ២៥ គម្រោង **នៅក្នុងចំណោមគម្រោងសរុបចំនួន ៣២ ដែលមានលក្ខណៈសម្បត្តិរួចរាល់** ដែលរួមមាន៖ ធនាគារពិភពលោកចំនួន ២ គម្រោង ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ៥ គម្រោង មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្មចំនួន ១ គម្រោង សាធារណរដ្ឋប្រជាមានិតចិនចំនួន៧គម្រោង ប្រទេសជប៉ុនចំនួន២គម្រោង សាធារណរដ្ឋកូរ៉េចំនួន ៣ គម្រោង សាធារណរដ្ឋបារាំងចំនួន ៣ គម្រោង ព្រះរាជាណាចក្រថៃចំនួន ១ គម្រោង និងសាធារណរដ្ឋឥណ្ឌាចំនួន ១ គម្រោង **ក្នុងគោលដៅទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម និងវែង ការលើកកម្ពស់ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ដែលរួមមាន៖**

- **វិស័យថាមពល៖** គម្រោងខ្សែបញ្ជូន៥០០គីឡូវ៉ុលជាឆ្អឹងខ្នងសម្រាប់បណ្តាញជាតិ និងភ្ជាប់អនុតំបន់ គម្រោងពង្រីកខ្សែបញ្ជូនអគ្គិសនីជនបទជំហានទី ៧ គម្រោងសាងសង់ខ្សែបណ្តាញថាមពលអគ្គិសនីតង់ស្យុង១១៥គីឡូវ៉ុលពីស្រុកសួងខេត្តត្បូងឃ្មុំទៅស្រុកស្វាយអន្ទរខេត្តព្រៃវែង គម្រោងធ្វើទំនើបកម្មលើប្រព័ន្ធបណ្តាញបញ្ជូន និងចែកចាយ កម្មវិធីថាមពលដើរដោយព្រះអាទិត្យសម្រាប់ការតភ្ជាប់ថាមពលអគ្គិសនី ក្នុងគោលដៅពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ ដើម្បីរួមចំណែកកាត់បន្ថយចំណាយរបស់ប្រជាជននៅជនបទផង និងកាត់-បន្ថយថ្លៃដើមផលិតកម្មក្នុងវិស័យកសិកម្ម និងសិប្បកម្ម/ឧស្សាហកម្មជនបទផង
- **វិស័យធារាសាស្ត្រ៖** គម្រោងអភិវឌ្ឍន៍ធនធានទឹកព្រែកស្ទឹងកែវខេត្តកំពតជំហានទី ២ គម្រោងកែលម្អធារាសាស្ត្រកសិកម្ម
- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** គម្រោងអភិវឌ្ឍន៍ផ្លូវពីសំឡូត-វាលវែង ទៅដល់កោះកុង គម្រោងសាងសង់ផ្លូវជាតិលេខ ៧១ (ត្បូងឃ្មុំ-ក្រូចឆ្មារ-ចំការលើ) គម្រោងសាងសង់ផ្លូវជាតិលេខ ៦០ ប្រវែង ១១៦ គម និងស្ពានមេគង្គក្រចេះ គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ផ្លូវជាតិលេខ៥ជំហានទី ២ គម្រោងធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ភាគខាងត្បូង និងភាគកណ្តាល គម្រោងកែលម្អផ្លូវជនបទជំហានទី៣ គម្រោងអភិវឌ្ឍន៍ផែទន្លេជំហានទី១ កម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់ប្រទេសកម្ពុជា និង
- **វិស័យអាទិភាពផ្សេងទៀត៖** គម្រោងក្នុងវិស័យកសិកម្ម សុខាភិបាល ការផ្គត់ផ្គង់ទឹកស្អាត ហិរញ្ញវត្ថុ បណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំ។

## សន្និធិបំណុលសាធារណៈក្រៅប្រទេស គិតត្រឹមដំណាច់ ខែកញ្ញា ឆ្នាំ ២០១៨




## អនុបាតបំណុលគន្លឹះទាំង ៤



## ៥- សេចក្តីសន្និដ្ឋាន

ការរៀបចំថវិកាឆ្នាំ ២០១៩ ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈម និងហានិភ័យមួយចំនួនក្តី ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជន៍សម្រាប់អាទិភាពគោលនយោបាយសំខាន់ៗជាសារវន្ត។ ក្នុងន័យនេះ **ថវិកាឆ្នាំ ២០១៩ នឹងដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការរក្សា ការពារ និងពង្រឹងថែមទៀតនូវសមិទ្ធផលដ៏ធំធេងដែលកម្ពុជាសម្រេចបានកន្លងមក ក៏ដូចជាក្នុងការបន្តបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត។** អាទិភាពចំណាយថវិកាឆ្នាំ២០១៩ គឺជាការឆ្លើយតបទៅនឹងអាទិភាព និងតម្រូវការចាំបាច់របស់ក្រសួង-ស្ថាប័ននានា ក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ខ្លួន ក៏ដូចជាគោលនយោបាយជាអាទិភាពរួមរបស់រាជរដ្ឋាភិបាល ដែលរួមមាន៖ ការអភិវឌ្ឍធនធានមនុស្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបញ្ចុះថ្លៃអគ្គិសនីនិងទឹកស្អាត ការជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់ ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រីកវិសាលភាព និងពង្រឹងគុណភាពនៃសេវាសាធារណៈគ្រប់ប្រភេទ ជាពិសេសសេវាអប់រំ សេវាសុខាភិបាល សេវាយុត្តិធម៌ និងសេវាមូលដ្ឋានចាំបាច់ដទៃទៀត និងការពង្រឹងសមត្ថភាពស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងការអនុវត្តរបបគាំពារសង្គម ដោយឈរលើគោលការណ៍ប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជន៍ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។

សរុបមក, ថវិកាឆ្នាំ ២០១៩ គឺត្រូវបានរៀបចំឡើងតាមគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation) ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើមនុស្ស និង ការកែទម្រង់រចនា-សម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូល ហើយអាចប្រសិទ្ធនាមបានថា ជា **“ថវិកាយុទ្ធសាស្ត្រនៃការរក្សាសមិទ្ធ-ផលដែលសម្រេចបានដោយលំបាក និងការបន្តបុកគ្រឹះថ្មីៗ សម្រាប់គាំទ្រដល់ការសម្រេចបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ និង យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល ដើម្បីបន្តរក្សាសន្តិភាព ស្ថេរភាព ក៏ដូចជាទ្រទ្រង់នូវដំណើរការវិវឌ្ឍឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍ ប្រកបដោយគុណភាព និង ចីរភាព តទៅមុខឥតឈប់ឈរ”** ។

*ថ្ងៃសុក្រ ២រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*

*រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨*

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ